

# ដំណើរស្វែងរកកោះនាគរាជ

The Asia Foundation - Let's Read

Buth Sonrin

Let's Read

The Asia Foundation



«ម៉ឹង ម៉ឹង ម៉ឹង!» បន្ទាប់ពីឮស្នូរជួងចេញលេង ស្រីល័ក្ខណ៍ទាញយកសៀវភៅក្របពណ៌លឿងមួយក្បាលចេញពីកាតាប រួចដើរចេញពីថ្នាក់រៀនយ៉ាងប្រញាប់ប្រញាល់។ នៅពេលនោះ រចនាស្រែកសួរស្រីល័ក្ខណ៍ថា៖ «ស្រីល័ក្ខណ៍ តើឯងចង់លេងជាមួយខ្ញុំទេ? ខ្ញុំមានការភ្ញាក់ផ្អើលមួយសម្រាប់ឯង។» ស្រីល័ក្ខណ៍រត់យ៉ាងលឿនសំដៅទៅទីធ្លាសាលា រួចស្រែកតបវិញថា៖ «សុំទោស! ខ្ញុំប្រញាប់ណាស់ ព្រោះមានកិច្ចការសំខាន់ត្រូវធ្វើ!»




ស្រីល័ក្ខណ៍រត់សំដៅទៅបណ្ណាល័យបណ្ដើរ គិតក្នុងចិត្តបណ្ដើរ៖ «វាប្រាកដជានៅទីនោះ។ វាត្រូវតែនៅទីនោះ!» យប់មិញ ស្រីល័ក្ខណ៍មិនបានគេងទេ ដោយសារនាងជក់ចិត្តអានសៀវភៅរឿងព្រេងនាគរាជ រហូតទាល់តែចប់។ ព្រេងនាគរាជ គឺជារឿងដែលទើបចេញថ្មីនៅក្នុងសេរីសៀវភៅដែលនាងចូលចិត្តអាន។



នៅប៉ុន្មានថ្ងៃមុន លោកគ្រូផានបានសន្យាជាមួយស្រីល័ក្ខណ៍ថា គាត់នឹងកុម្ម៉ង់សៀវភៅដែលទើបចេញថ្មីមកដាក់នៅក្នុងបណ្ណាល័យ។ សៀវភៅនោះមានចំណងជើងថា កោះនាគរាជ ។ ប៉ុន្តែស្រីល័ក្ខណ៍មិនប្រាកដថាលោកគ្រូផានបានកុម្ម៉ង់សៀវភៅនោះឱ្យនាងទេ ព្រោះគាត់គឺជាបណ្ណារក្សដែលធ្វើការស្ម័គ្រចិត្តនៅក្នុងបណ្ណាល័យរបស់សាលាតែពីរឬបីថ្ងៃប៉ុណ្ណោះក្នុងមួយសប្តាហ៍។



ស្រីល័ក្ខណ៍ស្ទុះចូលទៅក្នុងបណ្ណាល័យយ៉ាងត្រហេបត្រហប រួច សួរលោកគ្រូផានថា៖ «លោកគ្រូ! តើលោកគ្រូមានសៀវភៅនោះ ដែរឬទេ? ខ្ញុំពិតជាចង់អានរឿងនោះខ្លាំងណាស់។» លោកគ្រូ ផានញញឹម រួចតបវិញថា៖ «លោកគ្រូចាំថា បានដាក់សៀវភៅ កោះនាគរាជនៅលើធ្នើរ។ ចាំលោកគ្រូរកមើលសិន។» ស្រី ល័ក្ខណ៍ស្រែកឡើងថា៖ «សៀវភៅនោះមានក្របពណ៌ក្រហម!»



លោកគ្រូផានរកមើលលើធ្នើរ ក្នុងថតតុ និងឆែករកក្នុងគំនរសៀវភៅ ប៉ុន្តែរកមិនឃើញសៀវភៅនោះសោះ។



លោកគ្រូផានប្រាប់ស្រីល័ក្ខណ៍ថា៖ «សូមទោស! ប្រហែលជាមានអ្នកខ្ចីសៀវភៅនោះទៅបាត់ហើយ។ អ៊ីចឹង ប្អូនត្រូវរង់ចាំទាល់តែគេសងសៀវភៅនោះវិញ។» ស្រីល័ក្ខណ៍តបវិញថា៖ «ពិតជាស៊យមែន! ពីមុនក៏អ៊ីចឹង ឥឡូវក៏អ៊ីចឹងទៀត។ ខ្ញុំពិតជាចង់អានសៀវភៅនោះខ្លាំងណាស់។ តើលោកគ្រូដឹងទេថានរណាខ្ចីសៀវភៅនោះ? តើពេលណាគេសងវិញ?» លោកគ្រូផានតបវិញថា៖ «លោកគ្រូមិនដឹងទេ ព្រោះម្សិលមិញ លោកគ្រូមិនបាននៅបណ្ណាល័យ ហើយក៏គ្មានការកត់ត្រាថា នរណាជាអ្នកខ្ចីដែរ។» មុនពេលចេញទៅវិញ ស្រីល័ក្ខណ៍ដកដង្ហើមធំរួចនិយាយថា៖ «លោកគ្រូ! យើងគួរតែមានប្រព័ន្ធគ្រប់គ្រងដែលល្អជាងនេះ។»



ស្រីល័ក្ខណ៍ដើរត្រឡប់មកថ្នាក់រៀនវិញដោយទឹកមុខ
អស់សង្ឃឹម។ ស្រីល័ក្ខណ៍មកដល់ថ្នាក់រៀនស្របពេលដែល
អ្នកគ្រូស៊ីដាកំពុងស្រង់វត្តមានសិស្ស នៅក្នុងម៉ោងគណិតវិទ្យា។
«ស្រីល័ក្ខណ៍ អ្នកគ្រូស្ទើរតែដាក់អវត្តមានឯងទៅហើយ។»
អ្នកគ្រូស៊ីដាសម្លឹងមើលទឹកមុខដ៏ក្រៀមក្រំរបស់ស្រីល័ក្ខណ៍
ហើយនិយាយថា៖ «អូ! តើលោកគ្រូផានគ្មានសៀវភៅដែលឯង
ចង់អានទៀតហើយមែនទេ?» ស្រីល័ក្ខណ៍តបវិញថា៖ «ចាស
អ្នកគ្រូ! លោកគ្រូផានមិនទាំងដឹងថា នរណាជាអ្នកខ្ចីសៀវភៅ
នោះផង។ ហេតុអ្វីក៏យើងមិនអាចដឹងថា សៀវភៅទាំងនោះ
នៅឯណា?»



អ្នកគ្រូស៊ីដាតបវិញថា៖ «ប្រហែលជាប្អូនអាចរៀបចំបញ្ជីសៀវភៅមួយសម្រាប់កត់ត្រាការខ្ចី-សងសៀវភៅហើយ។» ស្រីល័ក្ខណ៍និយាយថា៖ «យើងចាំបាច់ត្រូវភ្ជាប់ឧបករណ៍តាមដានដូចដែលដានីបានធ្វើក្នុងសៀវភៅរឿងព្រេងនាគរាជអ៊ីចឹង។» អ្នកគ្រូស៊ីដាតបដោយលេងសើចថា៖ «គំនិតល្អ ប៉ុន្តែការដឹកជញ្ជូនឧបករណ៍ពីតំបន់ភ្នំនាគរាជមកទីនេះប្រហែលជាលំបាកណាស់។»



អ្នកគ្រូស៊ីដាចង្អុលបង្ហាញពីវិធីផ្សេងៗ ដែលគាត់បានរៀបចំ ដើម្បីតាមដាននៅក្នុងការគ្រប់គ្រងថ្នាក់រៀន។ គាត់រំឭកប្រាប់ ស្រីល័ក្ខណ៍ពីតារាងដែលព្យួរនៅលើជញ្ជាំង សម្រាប់បង្ហាញពី តារាងមេគុណដែលសិស្សបានរៀន។ គាត់ចង្អុលទៅតារាងនៅ លើក្ដារខៀន ដែលបង្ហាញពីបញ្ជីកិច្ចការដែលសិស្សត្រូវធ្វើ។ គាត់ក៏បង្ហាញពីតារាងកិច្ចការដែលត្រូវធ្វើ លើតុរបស់គាត់ផង ដែរ។



ស្រីល័ក្ខណ៍និយាយថា៖ «អ៊ីចឹង តើយើងអាចកត់ឈ្មោះសិស្ស និងចំណាងជើងសៀវភៅជាព័ត៌មាន នៅកន្លែងណាមួយបានដែរឬទេ?» អ្នកគ្រូស៊ីដាក៏ឆ្លើយតបវិញយ៉ាងរហ័សថា៖ «ល្អណាស់ ស្រីល័ក្ខណ៍! នោះជាអ្វីដែលអ្នកគ្រប់គ្រងមូលដ្ឋានទិន្នន័យត្រូវធ្វើ។»





ស្រីល័ក្ខណ៍សួរអ្នកគ្រូបន្ថែមថា៖ «តើមូលដ្ឋានទិន្នន័យមិនពាក់ព័ន្ធនឹងកុំព្យូទ័រទេឬអ្នកគ្រូ? តែយើងគ្រាន់តែកត់ឈ្មោះនៅលើក្រដាសហ្នឹង។» អ្នកគ្រូស៊ីដាតបវិញថា៖ «ចាស! អ្នកគ្រប់គ្រងមូលដ្ឋានទិន្នន័យមានកិច្ចការជាច្រើនទៀតដែលត្រូវធ្វើ ប៉ុន្តែគំនិតរួមនៃការងារនេះដូចតែគ្នាទេ គឺត្រូវរៀបចំប្រមូលផ្តុំព័ត៌មានដ៏ច្រើននោះឱ្យមានសណ្តាប់ធ្នាប់ ដើម្បីជាប្រយោជន៍ដល់អ្នកប្រើប្រាស់។»



ស្រីល័ក្ខណ៍ហាក់ដូចជាយល់ច្រើនជាងមុន។ នាងងាកមើលជុំវិញក្នុងថ្នាក់រៀន រួចដើរសំដៅទៅបណ្ណាល័យវិញ។ ចំណែកអ្នកគ្រូស៊ីដា ក៏ដើរតាមពីក្រោយនាង។



ស្រីល័ក្ខណ៍និយាយទៅកាន់លោកគ្រូផានថា៖ «លោកគ្រូ យើងត្រូវការមូលដ្ឋានទិន្នន័យមួយ ព្រោះយើងត្រូវដឹងថាសៀវភៅកោះនាគរាជនៅឯណា។» លោកគ្រូផាននិយាយដោយសម្លឹងមើលគំនរសៀវភៅនៅក្បែរនោះថា៖ «ឯងមានគំនិតល្អ! ប៉ុន្តែតើយើងត្រូវធ្វើយ៉ាងណា បើយើងគ្មានកុំព្យូទ័រផងហ្នឹង?»




ស្រីល័ក្ខណ៍ចង្អុលទៅជញ្ជាំង រួចនិយាយថា៖ «យើងមិនចាំបាច់មានកុំព្យូទ័រទេ។ យើងអាចសរសេរឈ្មោះអ្នកខ្ចី និងចំណងជើងសៀវភៅលើក្ដារខៀន រួចលុបវាចោលនៅពេលគេយកសៀវភៅមកសងវិញ។» ស្រីល័ក្ខណ៍ចាប់ផ្ដើមសរសេរចំណងជើងសៀវភៅកោះនាគរាជលើក្ដារខៀន។ អ្នកគ្រូស៊ីដាសួរថា៖ «ប៉ុន្តែបើមាននរណាម្នាក់លុបក្ដារខៀនចោលដោយចៃដន្យតើយើងត្រូវធ្វើដូចម្ដេច?» ស្រីល័ក្ខណ៍តបវិញថា៖ «បើអ៊ីចឹង តើយើងអាចសរសេរនៅលើសៀវភៅជំនួសវិញបានទេ? គឺវាដូចនឹងការកត់វត្តមានសិស្សនៅក្នុងថ្នាក់រៀនដែរ។»



លោកគ្រូផាននិយាយថា៖ «គំនិតល្អមែន! ក្រៅពីនេះ យើងគួរបន្ថែមព័ត៌មានអំពីថ្ងៃខែខ្ចីសៀវភៅ ដើម្បីឱ្យយើងដឹងពីរយៈពេលដែលគេខ្ចីសៀវភៅនីមួយៗ។» ស្រីល័ក្ខណ៍លាន់មាត់ថា៖ «បន្ទាប់មក ខ្ញុំនឹងដឹងពីពេលដែលគេសងសៀវភៅកោះនាគរាជមកវិញ។ ពួកគេគួរតែអានសៀវភៅនោះចប់ក្នុងរយៈពេលពីរថ្ងៃ ឬយ៉ាងច្រើនបីថ្ងៃប៉ុណ្ណោះ។» អ្នកគ្រូស៊ីដាសើច រួចនិយាយថា៖ «មែនហើយ! ប៉ុន្តែយើងគួរទុកពេលឱ្យគេខ្ចីសៀវភៅបានយូរជាងនេះបន្តិច។» លោកគ្រូផាននិយាយថា៖ «ចុងបញ្ចប់ យើងត្រូវបង្ហាញពីថ្ងៃខែដែលគេសងសៀវភៅមកបណ្ណាល័យវិញ។»



លោកគ្រូផានយកសៀវភៅមួយក្បាលដាក់លើតុ រួចសរសេរចំណងជើងបួនសំខាន់ៗនៅផ្នែកខាងលើនៃទំព័រសៀវភៅ។ អ្នកគ្រូសុខាសួរថា៖ «តើយើងអាចរក្សាមូលដ្ឋានទិន្នន័យរបស់យើងដោយរបៀបណា?» ស្រីល័ក្ខណ៍តបថា៖ «ខ្ញុំមិនសូវយល់ពីសំណួរអ្នកគ្រូទេ។» អ្នកគ្រូសុខាពន្យល់បន្ថែមថា៖ «តើធ្វើយ៉ាងណាទើបយើងអាចកត់ឈ្មោះអ្នកខ្ចីសៀវភៅ និងថ្ងៃខែឱ្យបានត្រឹមត្រូវ?» ស្រីល័ក្ខណ៍សួរលោកគ្រូផានថា៖ «តើលោកគ្រូអាចបញ្ចូលព័ត៌មានទាំងនេះបានដែរឬទេ?» លោកគ្រូផានតបវិញថា៖ «លោកគ្រូនឹងបង្រៀនឱ្យអ្នកផ្សេងទៀតចេះបញ្ចូលព័ត៌មានទាំងនេះ។ ដូច្នេះ ពួកគេនឹងចេះធ្វើវានៅពេលដែលលោកគ្រូមិននៅ។» ស្រីល័ក្ខណ៍លើកជាយោបល់ ដោយចង្អុល

ទៅគំនរសៀវភៅរបស់រប៉ាយថា៖ «ម៉្យាងវិញទៀត យើងអាច
ដាក់សញ្ញាសម្គាល់នៅកន្លែងគំនរសៀវភៅដែលគេយកមកសង
បណ្ណាល័យវិញ។»



នៅរសៀលថ្ងៃនោះ លោកគ្រូផានបានរៀបចំសៀវភៅ «បញ្ជីខ្ចី-សង» រួចរាល់ ចំណែកស្រីល័ក្ខណ៍ក៏រៀបចំសៀវភៅ និងធ្វើស្លាកសញ្ញាសម្គាល់ «ខ្ចីសៀវភៅនៅទីនេះ» បានរួចរាល់ដែរ។ ស្រីល័ក្ខណ៍និយាយថា៖ «ចាប់ពីពេលនេះទៅ យើងនឹងដឹងថាតើនរណាជាអ្នកខ្ចីសៀវភៅចំណងជើងណាហើយ! ប៉ុន្តែខ្ញុំនៅតែមិនអាចអានសៀវភៅកោះនាគរាជបាន។ ប្រហែលជាខ្ញុំត្រូវចាំបន្តទៀតហើយ។» បន្តិចក្រោយមក រចនា មិត្តរបស់ស្រីល័ក្ខណ៍ដើរចូលក្នុងបណ្ណាល័យ រួចនិយាយថា៖ «ជម្រាបសួរអ្នកគ្រូ លោកគ្រូ។ ស្រីល័ក្ខណ៍ តើឯងកំពុងធ្វើអ្វីហ្នឹង?» អ្នកគ្រូស៊ីដានិយាយថា៖ «ស្រីល័ក្ខណ៍បានបង្កើតបញ្ជីកត់ឈ្មោះអ្នកខ្ចីសៀវភៅពីបណ្ណាល័យ។»




រចនាក៏និយាយថា៖ «អូ! ម្សិលមិញ ខ្ញុំបានខ្ចីសៀវភៅមួយក្បាល។ ខ្ញុំឃើញសៀវភៅនោះនៅលើធ្នើរ ហើយខ្ញុំគិតថា ខ្ញុំចង់យកវាឱ្យឯងអានណា ស្រីល័ក្ខណ៍។» ស្រីល័ក្ខណ៍ និយាយដោយភ្ញាក់ផ្អើលថា៖ «សៀវភៅកោះនាគរាជ! អរគុណច្រើនសម្លាញ់។»



អ្នកគ្រូស៊ីដានិយាយទៅកាន់ស្រីល័ក្ខណ៍ថា៖ «ឥឡូវនេះ សូមសរសេរឈ្មោះប្អូនក្នុងសៀវភៅបញ្ជីខ្ចី-សង ដើម្បីឱ្យសិស្សផ្សេងទៀតដឹងថា ប្អូនជាអ្នកខ្ចីសៀវភៅកោះនាគរាជ។» ស្រីល័ក្ខណ៍រំភើបនឹងចាប់ផ្តើមអានសៀវភៅ ដែលចាប់ផ្តើមដោយសរសេរថា «អ័ព្ទគ្របដណ្តប់ពាសពេញផ្ទៃកោះ។»



Generously supported by Smart Axiata

Brought to you by

The Asia Foundation

Let’s Read is an initiative of The Asia Foundation’s Books for Asia program that fosters young readers in Asia and the Pacific.
booksforasia.org
To read more books like this and get further information about this book, visit letsreadasia.org

**Original Story**
*ដំណើរស្វែងរកកោះនាគរាជ (Finding Dragon Island)*, Author: The Asia Foundation - Let’s Read. Illustrator: Buth Sonrin. Published by The Asia Foundation - Let’s Read, © The Asia Foundation - Let’s Read. Released under CC-BY-NC-4.0.

This work is a modified version of the original story. © The Asia Foundation, 2020. Some rights reserved. Released under CC-BY-NC-4.0.

For full terms of use and attribution, http://creativecommons.org/licenses/by-nc/4.0/